អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន
YOUTH RESOURCE DEVELOPMENT PROGRAM ORGANIZATION
YRDP

# ការឆ្លើយតបទៅនឹងការអំពាវនាវឱ្យមានការចូលរួមចំណែកជាគំនិតស្តីពីមុខងារដែលនៅសេសសល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការតុលាការកម្ពុជា (អ.វ.ត.ក) ពាក់ព័ន្ធនឹងជនរងគ្រោះ

ចាប់តាំងពីឆ្នាំ១៩៩២ មក អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (ក.អ.ធ.យ) បានចូលរួមក្នុងការលើកស្ទួយសន្តិភាព និងយុត្តិធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាព។ តាមរយៈគម្រោង "ការចូលរួមរបស់យុវជនក្នុងការយល់ដឹងពីប្រវត្តិសាស្ត្រដើម្បីសន្តិភាព និងយុត្តិធម៌" (ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន) ក.អ.ធ.យ បានបំផុសឱ្យយុវជនស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈវគ្គបណ្តុះបណ្តាលក្នុងស្ថាប័ន និងការចុះតាមទីតាំងនៃការសម្លាប់រង្គាល ក៏ដូចជាការប្រើប្រាស់វិធីសាស្ត្ររៀនសូត្របែបនវានុវត្តន៍។ ការស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជាក្នុងមជ្ឈដ្ឋានជាក់ស្តែង ផ្តល់លទ្ធភាពឱ្យយុវជនកត់សម្គាល់ និងទទួលស្គាល់ភាពយង់ឃ្នងពីអតីតកាល និងផ្តួចផ្តើមដំណើរការឆ្លុះបញ្ចាំងស៊ីជម្រៅលើឫសគល់នៃជម្លោះនេះ។ បន្ទាប់មក មនុស្សជំនាន់ក្រោយនឹងរិះរកវិធីទប់ស្កាត់មិនឱ្យជម្លោះនេះកើតឡើងជាថ្មី ទទួលបានជំនាញត្រិះរិះពិចារណា និងឆ្លុះបញ្ចាំងពីភាពជាអ្នកដឹកនាំរបស់ពួកគេ។

ការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម នឹងជំរុញឱ្យយុវជនចោទសួរពីផលប៉ះពាល់នៃព្រឹត្តិការណ៍ពីអតីតកាលលើក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។ ដូច្នេះ កម្មវិធីសិក្សារបស់ ក.អ.ធ.យ នឹងបំពាក់បំប៉នឧបករណ៍ និងជំនាញដល់យុវជនក្នុងការស្វែងយល់ពីការប៉ះទង្គិចផ្លូវចិត្ត ការប្រឹក្សាយោបល់ជាមូលដ្ឋាន និងការយកចិត្តទុកដាក់ស្តាប់ ដើម្បីគាំទ្រដល់ការព្យាបាលរបួសស្នាមតាមរយៈកិច្ចសន្ទនាអន្តរជំនាន់។ ដំណើរការជួយព្យាបាលផ្លូវចិត្តនេះនឹងពង្រឹងទំនាក់ទំនងរវាងឪពុកម្តាយ និងកូន និងអន្តរកម្មរវាងសមាជិកគ្រួសារទាំងមូល។

ក្រៅពីការសិក្សាស្វែងយល់ ក.អ.ធ.យ មានគោលបំណងលុបបំបាត់ភាពភ័យខ្លាចរបស់មនុស្សជំនាន់ក្រោយក្នុងការប្រឡូកក្នុងជីវភាពនយោបាយ និងជីវភាពសង្គម។ ក.អ.ធ.យ ចង់ផ្តល់លទ្ធភាពឱ្យយុវជនចូលរួមយ៉ាងសកម្មក្នុងដំណើរការផ្សះផ្សារជាតិនៅកម្ពុជា តាមរយៈការបណ្តុះបណ្តាល បូករួមនឹងគម្រោងផ្លាស់ប្តូរយុវជន កម្មវិធីជជែកកំសាន្តតាមវិទ្យុ និងសកម្មភាពឆ្លុះបញ្ចាំងស៊ីជម្រៅផ្សេងទៀត។ ក.អ.ធ.យ ផ្តោតលើប្រធានបទនានា ដូចជា ពហុបក្ស ជាតិនិយម ផ្ទុត់គំនិត និងភាពលម្អៀង។ ការសិក្សាស្វែងយល់តាមរយៈការប្រើប្រាស់

ការត្រិះរិះពិចារណា ត្រូវបានប្រើប្រាស់ជាវិធីសាស្ត្រសម្រាប់ការឆ្លុះបញ្ចាំងពីបរិបទសង្គមនយោបាយបច្ចុប្បន្ន ដើម្បីឱ្យយុវជនមានឱកាសពិចារណាស៊ីជម្រៅឡើងវិញ និងច្បាមយកមេរៀនសំខាន់ៗបំផុតពីប្រវត្តិសាស្ត្រ ដើម្បីលើកស្ទួយសន្តិភាព និងការផ្សះផ្សារក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។

នៅក្នុងបរិបទនេះ និងដោយយល់ថា ប្រតិបត្តិការរបស់ អ.វ.ត.ក ជិតបិទបញ្ចប់មុខងារនៅសេសសល់មួយដែលត្រូវផ្តោតការយកចិត្តទុកដាក់ដើម្បីពង្រឹងមូលដ្ឋានសង្គមសេដ្ឋកិច្ច គឺការផ្សព្វផ្សាយព័ត៌មានស្តីពីយន្តការយុត្តិធម៌អន្តរកាល កិច្ចដំណើរការនីតិវិធី និងសមិទ្ធផលរបស់ អ.វ.ត.ក ដល់មនុស្សជំនាន់ក្រោយ។ ការប្រើប្រាស់ អ.វ.ត.ក និងមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក (ម.ត.ឯ.ច) ជាវេទិការៀនសូត្រសម្រាប់សិស្សនិស្សិត នឹងដើរតួនាទីសំខាន់ក្នុងការបង្កើតវគ្គអប់រំស្តីពីសន្តិភាពដែលបង្កផលប៉ះពាល់ខ្លាំង និងក្តោបជារួម តាមរយៈការគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះការកសាងសន្តិភាព និងការផ្តល់យុត្តិធម៌ដល់ប្រជាជនកម្ពុជា។ ទន្ទឹមនឹងនេះ ដំណើរទស្សនកិច្ចរបស់សិស្សនិស្សិតទៅកាន់ អ.វ.ត.ក និង ម.ត.ឯ.ច នឹងធានាថា សាធារណជនអាចប្រើប្រាស់បណ្ណសារយ៉ាងទូលំទូលាយ។ នេះជាមុខងារនៅសេសសល់ដ៏សំខាន់ក្នុងការពង្រឹងការផ្សះផ្សារ និងការកសាងឡើងវិញបានយ៉ាងប្រសើរ។

ក.អ.ធ.យ ត្រៀមខ្លួនជាស្រេចក្នុងការគាំទ្រដល់ការផ្សព្វផ្សាយពីការងាររបស់ អ.វ.ត.ក កេរដំណែល និងមុខងារនៅសេសសល់របស់ អ.វ.ត.ក ដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះ អ្នករស់រានមានជីវិត និងកូនចៅរបស់ពួកគេ។ តាមរយៈមុខងារដែលនៅសេសសល់ទាំងនេះ អ.វ.ត.ក នឹងមានឱកាសពង្រឹងកិច្ចសហប្រតិបត្តិការ និងការចូលរួមរបស់អ្នកដឹកនាំជំនាន់ក្រោយរបស់កម្ពុជាដែលជាអ្នកស្នងកេរដំណែលរបស់ អ.វ.ត.ក និងបង្រួបបង្រួមកិច្ចខិតខំប្រឹងប្រែងផ្សះផ្សារ។

សកម្មភាពដែលស្នើឡើងសម្រាប់ឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ ៖

- ផ្តល់ការបណ្តុះបណ្តាលក្នុងស្ថាប័ន និងចុះទៅតាមទីតាំង ស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការផ្សះផ្សារ
- ដំណើរទស្សនកិច្ចទៅកាន់តំបន់អន្លង់វែង
- ដំណើរទស្សនកិច្ចទៅកាន់ អ.វ.ត.ក
- ដំណើរទស្សនកិច្ច និងការចុះស្រាវជ្រាវនៅ ម.ត.ឯ.ច
- កិច្ចសន្ទនាក្នុងសហគមន៍ជាមួយជនរងគ្រោះនៃរបបខ្មែរក្រហម ដើម្បីការផ្សះផ្សារ និងសន្តិភាព
- ការប្រាប់ការពិត ៖ ការរៀបចំពិព័រណ៍គ្រួសារប្រកបដោយភាពច្នៃប្រឌិត

- កិច្ចសន្ទនាអន្តរជំនាន់ស្តីពីការប្រឈមមុខជាមួយអតីតកាល
- កម្មវិធីជជែកកម្សាន្តតាមវិទ្យុស្តីពីបញ្ហាកង្វល់ (ទម្លាយភាពស្ងៀមស្ងាត់)